# របាយការណ៍ប្រចាំខែកុម្ភៈ ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ

នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៥ មន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ បានបំពេញភារកិច្ចសម្រេចលទ្ធផលដូចខាងក្រោម÷

1. <u>ស្ថានភាពមន្ត្រីរាជការ</u>÷

ស្ថានភាពមន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ សរុបចំនួន ៣០ នាក់ ស្ត្រី ០៤ នាក់ និងដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអនុប្រធានមន្ទីរ ០២ រូប ។

2. <u>សកម្មភាពថ្នាក់ដឹកនាំមន្ទីរ</u>÷

- ចូលរួមប្រជុំប្រចាំឆ្នាំស្តីពីកម្មវិធីផែនការសុវត្ថិភាពទឹកផឹកជនបទ និងពិនិត្យប្លង់បច្ចេកទេសដំបូង តម្លៃប៉ាន់ស្មានផ្លូវកៅស៊ូ២ជាន់ និងសំណង់ដែលក្រុមហ៊ុនបានចុះកិច្ចសន្យានៅរាជធានីភ្នំពេញ នៅថ្ងៃទី២៩/០១/២០១៥
- ចូលរួមប្រជុំបើក និងពិនិត្យវាយតម្លៃឯកសារដេញថ្លៃផ្លូវថែទាំ ឆ្នាំ ២០១៥ សម្រាប់កម្មវិធី RIPIII នៅថ្ងៃទី០៥/០២/២០១៥ នៅរាជធានីភ្នំពេញ
- ចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៤ និងទិសដៅការងាររបស់ក្រសួងនៅថ្ងៃទី១២/០២/២០១៥
- ចូលរួមវេទិកាសាធារណៈដើម្បីត្រួតពិនិត្យ និងការគ្រាំទ្រអនុវត្តកម្មវិធីគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់ទី៣ នៅឃុំក្បាលដំរី ស្រុកសំបូរ ថ្ងៃទី២០/០២/២០១៥
- ចូលរួមក្នុងពិធីបើកការប្រកួតកីឡាសិស្ស ថ្ងៃទី០៦/០២/២០១៥ និងបិទនៅថ្ងៃទី១២/០២/២០១៥ នៅពហុកីឡាដ្ឋានខេត្ត
- ចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៤ របស់រដ្ឋបាលសាលាខេត្ត នៅថ្ងៃទី១០-១១/០២/២០១៥ នៅសាលមហោស្រពខេត្ត
- ចូលរួមប្រកាសតែងតាំងនាយខណ្ឌរដ្ឋបាលព្រៃឈើខេត្ត និងប្រធានមន្ទីរសង្គមកិច្ច ថ្ងៃទី១២/០២/២០១៥ នៅសាលាខេត្តក្រចេះ
- ចូលរួមប្រជុំបូកសរុបលទ្ធផលការងារលើគ្រប់វិស័យប្រចាំខែមករា ឆ្នាំ២០១៥ របស់រដ្ឋបាលសាលាខេត្ត នៅថ្ងៃទី១៣/០២/២០១៥
- ចូលរួមក្នុងពិធីប្រកាសតែងតាំងប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត ថ្ងៃទី១៦/០២/២០១៥
- ចូលរួមប្រគល់វិញ្ញាបនបត្រសម្គាល់អចលវត្ថុនៅឃុំដំរីផុង ស្រុកឆ្លូង ថ្ងៃទី២៣/០២/២០១៥
- ចូលរួមប្រជុំក្រុមការងារគណៈកម្មការបុណ្យទន្លេ ថ្ងៃទី២១/០២/២០១៥ នៅសាលាខេត្ត ។

3. <u>សកម្មភាពតាមការិយាល័យ</u>÷

3.1. <u>ការិយាល័យរដ្ឋបាល និងបុគ្គលិក</u>÷

ក. <u>ផ្នែកការងារលិខិតចូល</u> ÷ សរុបចំនួន ៥៥ លេខ ក្នុងនោះមានៈ

- លិខិតរបស់រាជរដ្ឋាភិបាល ចំនួន ០០ លេខ

- លិខិតរបស់ក្រសួងសាមី ចំនួន ០៦ លេខ
- លិខិតក្រសួងនានា ចំនួន ០៧ លេខ
- លិខិតផ្សេងៗក្នុងខេត្ត ចំនួន ៤២ លេខ

ខ. <u>ផ្នែកការងារលិខិតចេញ</u>÷ សរុបចំនួន ១៩ លេខ ក្នុងនោះមាន:

- លិខិតទៅនាយកដ្ឋាន និងក្រសួង ចំនួន ០៥ លេខ
- លិខិតផ្សេងៗទូទៅ ក្នុងខេត្ត ចំនួន ១៤ លេខ
- ស្ថាប័ននានា ចំនួន ០០ លេខ

គ. <u>ផ្នែកការងារលិខិតបញ្ជាបេសកកម្ម</u>÷ សរុបចំនួន ១៨ លេខ

- ធ្វើសំណើសុំលិខិតបញ្ជាបេសកម្មលោកប្រធានមន្ទីរ ពី **ឯកឧត្តមអភិបាលខេត្ត** ចំនួន ០២ លេខ
- ចេញលិខិតបញ្ជាបេសកកម្មជូនមន្ត្រី ចំនួន ១៦ លេខ

ឃ. <u>ផ្នែកបញ្ជីវត្តមាន</u>÷

- ពិនិត្យការចុះបញ្ជីវត្តមានជាប្រចាំថ្ងៃ ។

## 3.2. <u>ការិយាល័យផ្លូវលំជនបទ</u>÷

- ចូលរួមពិនិត្យ និងសិក្សាផលប៉ះពាល់ដីរបស់ប្រជាពលរដ្ឋ នៅលើទីតាំងស្នើសុំផ្លូវចូលក្នុងក្រុមហ៊ុន ស៊ី និងវីគ្រុប នៅឃុំរលួសមានជ័យ ស្រុកសំបូរ
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយ និងបូកសរុបលទ្ធផលការងាររៀបចំបញ្ជីសារពើភ័ណ្ឌផ្លូវជនបទ ឆ្នាំ ២០១៥ របស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បញ្ជាក់បច្ចេកទេសគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៥ របស់សាលាខេត្ត ទីចាត់ការផែនការ និងវិនិយោគ បានចំនួន ១ គម្រោង
- ចុះស្រង់ទិន្នន័យយានដ្ឋានរថយន្តកែច្នៃដឹកទំនិញធុនធ្ងន់ ស្រុកឆ្លូង ស្រុកចិត្របុរី ស្រុកស្នួល ក្រុងក្រចេះ ។

## 3.3. <u>ការិយាល័យផ្គត់ផ្គង់ទឹកជនបទ</u>÷

- ធ្វើយុទ្ធនាការផ្សព្វផ្សាយអំពីការបន្សុទ្ធទឹក និងការទុកដាក់ទឹកអោយមានសុវត្ថិភាពតាមគ្រួសារនៅភូមិប្រឡាយទ្រៀក ១២០ គ្រួសារ និងភូមិក្រូច ១២០ គ្រួសារ ឃុំដីវីផុង ស្រុកឆ្លូង
- ចុះពិនិត្យការសាងសង់ឃឿនអណ្តូងស្នប់នៅភូមិប្រម៉ា ឃុំដីវីផុង ទទួលបាន ៧០% ។

## 3.4. <u>ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ</u>÷ (គ្មានសកម្មភាព)

## 3.5. <u>ការិយាល័យអភិវឌ្ឍន៍សហគមន៍</u>÷ (គ្មានសកម្មភាព)

## 3.6. <u>ការិយាល័យជនជាតិដើមភាគតិច</u>÷ (គ្មានសកម្មភាព)

## 3.7. <u>ការិយាល័យថែទាំសុខភាពជនបទ</u>÷ (គ្មានសកម្មភាព)

3.8. <u>ការងារបណ្តុះបណ្តាលមន្ត្រីរាជការ</u>÷

- លោក ម៉ៅ សុខជា អនុប្រធានមន្ទីរ បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់តម្រង់ទិសថ្នាក់ជាតិ ស្តីពីក្របខ័ណ្ឌលទ្ធផលនៃផែនការ សកម្មភាពសម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាតជនបទ ឆ្នាំ២០១៤-២០១៨ ចាប់ពីថ្ងៃទី ០៥ ដល់ថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០១៥ នៅរាជធានីភ្នំពេញ ក្រោមការឧបត្ថម្ភដោយក្រសួងអភិវឌ្ឍន៍ជនបទ។
- លោក សន ធី ប្រធានការិយាល័យហិរញ្ញវត្ថុ និង ធន បូនិត (ស្រី) មន្ត្រីការិយាល័យហិរញ្ញវត្ថុ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពី ការផ្សព្វផ្សាយរជ្ជទេយ្យបុរេប្រទានថវិកាកម្មវិធី ឆ្នាំ២០១៥ កាលពីថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០១៥ នៅមន្ទីរសេដ្ឋកិច្ចកំពង់ចាម ក្រោមការឧបត្ថម្ភដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

4. <u>ទិសដៅបន្ត</u>÷

- ចុះស្រង់ទិន្នន័យផ្លូវតាមប្រព័ន្ធ GPS ក្នុងស្រុកស្នួល ដើម្បីរៀបចំបញ្ជីសារពើភ័ណ្ឌផ្លូវ និងផែនទីក្នុងខេត្តក្រចេះ
- បន្តធ្វើយុទ្ធនាការផ្សព្វផ្សាយអំពីការបន្សុទ្ធទឹក និងការទុកដាក់ទឹកអោយមានសុវត្ថិភាពតាមគ្រួសារ
- បន្តចុះពិនិត្យការសាងសង់ឃឿនអណ្តូងស្នប់នៅឃុំដំរីផុង ។

**ប្រធានមន្ទីរ**